Ministry of Commerce
N° 2081.MOC.D./ICO

**KINGDOM OF CAMBODIA**
**Nation - Religion - King**

# LIST OF THE STRATEGIC PROPOSALS APPROVED

By the 33rd Implementation Committee Meeting
Ministry of Commerce, 10 June 2014

| No. | Strategic Proposal Code | Strategic Proposal Title | Implementing Agency | Ministry | Pillars | Budget (USD) | 33rd IC Recommendation |
|---|---|---|---|---|---|---|---|
| 1 | TDSP2014 -SP10 | Streamlining and Automation of Business Registration | Department of Business Registration | Ministry of Commerce | 1 | 399,398.00 | Approval for 2014-2015 |
| 2 | TDSP2014 -SP11 | Automation of Phyto-Sanitary Certificates | General Directorate of Agriculture | Ministry of Agriculture, Forestry and Fisheries | 1 | 392,800.00 | Approval for 2014-2015 |

Phnom Penh, 19 June 2014

**Seen & Approved by**

**TEKRETH Kamrang**
Secretary of State
Trade SWAp IC Chair

Prepared by

**CHHIENG Pich**
Director of DICO, TDSP & EIF

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
អគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ
នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ
លេខ:...០៩៣.................សហអ

**សូមគោរពជូន**
**ឯកឧត្តម ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**តាមរយៈ:** *លោកជំទាវរដ្ឋលេខាធិការ ទទួលបន្ទុក* DICO
**កម្មវត្ថុ:** *របាយការណ៍នៃកិច្ចប្រជុំគណៈកម្មការអនុវត្តគម្រោងលើកទី៣៣*
**យោង:** *- លិខិតអញ្ជើញរបស់ក្រសួងពាណិជ្ជកម្ម*
*- កម្មវិធីកិច្ចប្រជុំប្រចាំឆ្នាំ ២០១៤ របស់* Trade SWAp

*សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទមានកិត្តិយស សូមគោរព ជម្រាបជូន* **ឯកឧត្តម ទេសរដ្ឋមន្ត្រី** *មេត្តាជ្រាបថា: គណៈកម្មាធិការអនុវត្តគម្រោង* IC (Implementing Committee) *បានរៀបចំកិច្ចប្រជុំប្រចាំខែរបស់ខ្លួនកាលពីថ្ងៃទី១០ ខែមិថុនា ឆ្នាំ ២០១៤ វេលាម៉ោង ៩:០០ ព្រឹក នៅក្រសួងពាណិជ្ជកម្ម ។ ខ្ញុំបាទសូមអនុញ្ញាតរាយការណ៍ ជូននូវចំណុចសំខាន់ៗ នៃកិច្ចប្រជុំខាងលើនេះ មានដូចខាងក្រោម ៖*

## I. **របាយការណ៍វឌ្ឍនភាពក្នុងក្របខ័ណ្ឌ TDSP**

ក). ស្ថានភាពទូទៅនៃការអនុវត្តគម្រោង:

- *គម្រោង* TDSP *បានចុះហត្ថលេខានៅថ្ងៃទី ១៤ ខែមករា ឆ្នាំ២០០៩ និងត្រូវបានអនុវត្តនៅថ្ងៃទី៩ ខែមីនា ឆ្នាំ២០០៩ ។* TDSP *ត្រូវបានបន្តជាលើកទី ២ ឲ្យអនុវត្ត រហូតដល់ថ្ងៃទី*

៣១ ខែមីនា ឆ្នាំ ២០១៥ (គួរកត់សម្គាល់ផងដែរថា កាលពីលើកទី១ គម្រោង TDSP ត្រូវបានបន្តឲ្យ អនុវត្តត្រឹមថ្ងៃទី ៣១ ខែមករា ឆ្នាំ២០១៤) ។

- ○ គម្រោង TDSP បានទទួលថវិកាបន្ថែមចំនួន $5,800,000 ក្នុងនោះ ៖
  - ✓ ថវិកាចំនួន $2,700,000 ត្រូវបានបែងចែកទៅឲ្យធនាគារពិភពលោក ក្នុងការអនុវត្តនូវគម្រោងមួយចំនួន ដែលស្ថិតនៅក្រោម Bank Executed Trust Fund (BETF) ។
  - ✓ ហើយថវិកាចំនួន $3,100,000 ត្រូវបានប្រគល់ជូនរាជរដ្ឋាភិបាល ក្នុងការអនុវត្តគម្រោង TDSP បន្តទៀត (Recipient Executed Trust Fund = RETF)
- ○ ថវិកាខាងលើនេះ ត្រូវបានបែងចែកក្នុងការអនុវត្តគម្រោងថ្មីៗ មួយចំនួនដូចមានខាងក្រោម:

| No. | Project | Implementing Agency | Amount |
|---|---|---|---|
| 1 | Trade Training and Research Institute (TTRI) | MoC | $500,000 |
| 2 | CO Automation and Service Portal | MoC | $550,000 |
| 3 | Business Registration | MoC | $350,000 |
| 4 | SPS (Sanitary and Phyto-Sanitary) | MAFF | $200,000 |
| 5 | Implementation support and M&E | MoC | $1,500,000 |
| **GRAND TOTAL** | | | **$3,100,000** |

## ខ). ការងារថវិកា:

- ➢ គិតចាប់ពីពេលអនុវត្តន៍គម្រោងដំបូង ពីឆ្នាំ ២០០៩ រហូតដល់ថ្ងៃ៣០ ខែមេសា ឆ្នាំ ២០១៤ នេះយើងបានធ្វើការចំណាយសរុបចំនួនតែ ៥៥% នៃជំនួយសរុប ($៨,៨៤៣,៥១៧ ចេញពី $១៥,៨៥០,០០០) ។
- ➢ ដោយបូករួមជាមួយថវិកាបន្ថែមចំនួន $3,100,000 នោះយើងមានថវិកាប្រមាណ $៧,០០៦,៤៨៣ ដែលត្រូវចំណាយក្នុងរយៈពេល ៩ខែ ខាងមុខនេះ ។ ចំណុចដែលយើងត្រូវយកចិត្តទុកដាក់នោះគឺនៅត្រង់ថា យើងត្រូវចំណាយប្រហែល $600,000 ក្នុងមួយខែ ទើបយើងអាចចាយអស់ប្រាក់ខាងលើ ។

## គ). ស្ថានភាពទូទៅនៃគម្រោង:

✓ មានគម្រោងចំនួន ៥ ដែលត្រូវបានបញ្ចប់ជាស្ថាពរ រួមមាន: Top Ten Products (TPD); Development of Trade Curriculum (RSA); Value Chain Information Unit (TPD); Export and SME Training (TPD); Capacity Building for DTSI (DTSI/MoC) ។

✓ មានគម្រោងចំនួន ៥ ដែលកំពុងរៀបចំបិទជាផ្លូវការ រួមមាន:

| Project | Agency | Approved Budget | Actual Expense | Balance | % Expense |
|---|---|---|---|---|---|
| Customs Valuation | GDCE | 50,000 | 44,232 | 5,768 | 88% |
| Awareness Program on Customs in Cambodia | GDCE | 95,000 | 21,001 | 73,998 | 22% |
| GDCE Capacity Enhancement Program | GDCE | 613,105 | 195,482 | 409,642 | 32% |
| Raising awareness on the Investment law | CDC | 195,860 | 93,740 | 102,119 | 48% |
| Enhancing IP Teaching and Training | NCIPR | 110,000 | 110,539 | (539) | 100.49% |
| TOTAL: | | | | 591,527 | - |

## II. របាយការណ៍វឌ្ឍនភាពក្នុងក្របខ័ណ្ឌ EIF

### ក). គម្រោងពង្រឹងសមាហរណកម្មជំហ៊ានទី១ (EIF Tier 1):

✓ចាប់ផ្តើមខែ កុម្ភៈ ២០១០

✓បញ្ចប់នៅខែ មិថុនា ២០១៥

✓ថវិកាគម្រោងដំណាក់កាលទី១: $909,900

✓ថវិកាគម្រោងដំណាក់កាលទី2: $584,000

✓ថវិកាគម្រោងដំណាក់កាលទី1&2: $ 1,493,900

✓សរុបថវិកាគម្រោងដែលទទួលបាន: $910,605.73

✓សរុបថវិកាដែលបានចំណាយ: $861,118.89ៗ ក្នុងនោះសម្រាប់ឆ្នាំ២០១០ ចំណាយអស់ $12,844 ឆ្នាំ២០១១ចំណាយអស់ $192,991 ឆ្នាំ២០១២ចំណាយអស់ $313,290 ឆ្នាំ២០១៣ ចំណាយអស់ $284,826 និងរហូតមកដល់ខែមីនា ឆ្នាំ២០១៤នេះ គឺចំណាយអស់ $57,165ៗ

✓សកម្មភាពរីកចម្រើនសំខាន់ៗរបស់គម្រោងរួមមានដូចជា:

- ➢ គាំទ្រការបណ្តុះបណ្តាលភាសាអង់គ្លេសដល់មន្ត្រី DICO និងក្រសួងនានា

- រៀបចំសិក្ខាសាលាស្តីពីការពង្រឹកពិពិធកម្មនាំចេញសម្រាប់មន្ត្រីក្រសួងពាណិជ្ជកម្ម
- គាំទ្រដល់ការរៀបចំប្រជុំ IC និង SSC
- រៀបចំរបាយការណ៍ប្រចាំឆ្នាំ ២០១៣ របស់ EIF Tier 1
- បោះពុម្ពនូវរបាយការណ៍សង្ខេប CTIS 2014-2018 ជាភាសាខ្មែរ និងអង់គ្លេស
- គាំទ្រដល់ការរៀបចំសម្ពោធជាផ្លូវការ CTIS 2014-2018
- គាំទ្រដល់ការរៀបចំសម្ពោធជាផ្លូវការ CEDEP II
- ធ្វើការជាមួយក្រុមបេសកកម្មរបស់ ES & TFM.
- គាំទ្រដល់ការកែសម្រួលផែនការសកម្មភាព និងផែនការថវិកា ព្រមទាំងផែនការកសាងសមត្ថភាពសម្រាប់ឆ្នាំ២០១៣-២០១៥។

ខ). គម្រោងពង្រឹងសមាហរណកម្មជំហានទី២ (EIF Tier 2): រួមមានពីរផ្នែកគឺ៖

✓CEDEP I ផ្តោតលើវិស័យចំនួន ៣ គឺវិស័យអង្ករ (IFC) វិស័យសូត្រ (ITC) និងការត្រួតពិនិត្យ និងវាយតម្លៃ (DICO)។

✓CEDEP II ផ្តោតលើវិស័យចំនួន ៣ គឺវិស័យដំឡូងមី (UNDP) ជលផល (UNIDO) រាជបណ្ឌិតសភាធ្វើម្ហូប (Shift 360) និងការត្រួតពិនិត្យ និងវាយតម្លៃ (DICO)។

✓នៅពេលអនាគត យើងនឹងអាចមានគម្រោង CEDEP III ដែលផ្តោតលើវិស័យមួយចំនួន ដូចជា វិស័យពោងចក្រធុនស្រាល វិស័យកៅស៊ូ វិស័យកែច្នៃផលិតផលកសិកម្ម ។ល។ នៅថ្ងៃទី១៨ ខែមិថុនា នេះ នឹងមានកិច្ចប្រជុំក្រុមប្រឹក្សាភិបាល EIF ដើម្បីពិភាក្សាពីការរៀបចំគម្រោង CEDEP III ។ គម្រោង CEDEP III នឹងផ្តោតលើវិស័យសំខាន់ៗចំនួនបី រួមមានវិស័យពោងចក្រធុនស្រាល, វិស័យកៅស៊ូ និងវិស័យកែច្នៃកសិផល ។ គម្រោងថវិកាសម្រាប់វិស័យនីមួយៗ អាចទទួលបានប្រមាណ ១ លានដុល្លារ ។

## III. បទបង្ហាញអំពីជំហានដែលត្រូវអនុវត្តសម្រាប់ការរៀបចំគម្រោងថ្មី

រាល់ការរៀបចំគម្រោងថ្មីៗ គឺយើងចាំបាច់ត្រូវអនុវត្តនូវជំហានមួយចំនួនដូចខាងក្រោម:

- រៀបចំសំណុំឯកសារមួយចំនួនរួមមាន ទស្សនទានគម្រោង ផែនការថវិកា ផែនការសកម្មភាព និងក្របខណ្ឌលទ្ធផល ។
- ការអនុម័តលើគម្រោងសំណើដោយ IC ហើយបន្ទាប់មកអនុម័តដោយ SSC

- បង្កើតក្រុមការងារអនុវត្តគម្រោង ដោយយ៉ាងហោចណាស់ត្រូវមានមន្ត្រីទទួលចំនួនប្រាំ គឺ: នាយកគម្រោង និងអនុប្រធាន, មន្ត្រីចេញវិញ្ញាបនប័ត្រ និងជាអនុប្រធាន, និងមន្ត្រីហិរញ្ញវត្ថុ(ជនបង្គោល)។
- អនុស្សារណៈយោគយល់គ្នានឹងត្រូវបានចុះហត្ថលេខារវាង DICO និង IAs ហើយបន្ទាប់មកគម្រោងគឺអាចចាប់ផ្តើមអនុវត្ត។
- ដើម្បីបង្កើនល្បឿនការអនុវត្តគម្រោង នោះតម្រូវអោយ IAs រៀបចំ និងផ្តល់នូវឯកសារមួយចំនួនមក DICO មានដូចជា: លក្ខខណ្ឌការងារសម្រាប់តំណែងទីប្រឹក្សា (ToR) និង Specification សម្រាប់ឧបករណ៍ ឬសម្ភារៈដែលត្រូវទិញ។
- DICO និងរៀបចំវគ្គបណ្តុះបណ្តាលដល់ IAs នូវជំនាញគ្រប់គ្រងហិរញ្ញវត្ថុ និងការត្រួតពិនិត្យ និងវាយតម្លៃ។ល។

## IV. បទបង្ហាញរបស់នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម (Business Registration Department)

គម្រោងស្វ័យប្រវត្តិកម្មចុះបញ្ជីពាណិជ្ជកម្ម បានរៀបចំឡើងដោយផ្អែកលើលទ្ធផលនៃការវាយតម្លៃ និងអនុសាសន៍របស់ជំនាញការមកពីធនាគារពិភពលោក ដែលមានធ្វើឡើងនៅចន្លោះខែតុលា ២០១៣ ដល់ ខែកុម្ភៈ ឆ្នាំ២០១៤។

- ឈ្មោះគម្រោង: Streamlining and Automation of Business Registration
- ភ្នាក់ងារអនុវត្តគម្រោង: Business Registration Department, MoC
- ថ្ងៃចាប់ផ្តើមគម្រោង: ខែ មិថុនា ២០១៤
- ថ្ងៃបញ្ចប់គម្រោង: ខែ មីនា ២០១៥
- ថវិកាគម្រោង: **$399,398**
- លទ្ធផលរំពឹងទុករយៈពេលមធ្យម: មានប្រាំចំណុចដូចខាងក្រោម:
  - ✓ រៀបចំឡើងវិញនូវនីតិវិធីនានា ដោយធ្វើឲ្យមានការងាយស្រួលក្នុងការដាក់ពាក្យ, ការប្រតិបត្តិ, និងការអនុម័ត នៃឯកសារដែលពាក់ព័ន្ធ
  - ✓ ស្វ័យប្រវត្តិកម្មនៃការចុះបញ្ជីពាណិជ្ជកម្ម ដោយច្របាច់បញ្ចូលគ្នាឲ្យទៅជា Database តែមួយ, ផ្តល់សេវាកម្មស្រាវជ្រាវរកឈ្មោះក្រុមហ៊ុន Online និងការទូទាត់តាមអេឡិចត្រូនិក (E-payment)

✓ កែទម្រង់ច្បាប់និងលិខិតបទដ្ឋាននានាដែលទាក់ទងនឹងផ្នែកនេះ

✓ ការចែករំលែកព័ត៌មានដល់ស្ថាប័នដទៃទៀត

✓ និរន្តរភាពនៃស្ថាប័ន និងជាគំរូក្នុងកម្រៃសេវា

លទ្ធផលរំពឹងទុករយៈពេលវែងនៃគម្រោងនេះ គឺកាត់បន្ថយពេលវេលា និងការចំណាយសម្រាប់សហគ្រិនក្នុងការបង្កើតអាជីវកម្មថ្មីនៅក្នុងប្រទេសកម្ពុជា។

**អង្គប្រជុំ IC បានអនុម័តលើគម្រោងស្នើនេះ។**

## V. បទបង្ហាញរបស់អគ្គនាយកដ្ឋានកសិកម្ម GDA (General Directorate of Agriculture)

គម្រោងស្វ័យប្រវត្តិកម្មវិញ្ញាបនប័ត្រអនាម័យ និងភូតគាមអនាម័យ បានរៀបចំឡើងដោយផ្អែកលើលទ្ធផលនៃការវាយតម្លៃ និងអនុសាសន៍ របស់ជំនាញការផ្នែក ICT និងជំនាញការផ្នែកអនាម័យ និងភូតគាមអនាម័យ នៃធនាគារពិភពលោក។

- ឈ្មោះគម្រោង: Automation of Phyto-sanitary Certificates
- ភ្នាក់ងារអនុវត្តគម្រោង: General Directorate of Agriculture (GDA), MAFF
- ថ្ងៃចាប់ផ្តើមគម្រោង: ខែ មិថុនា ២០១៤
- ថ្ងៃបញ្ចប់គម្រោង: ខែ មីនា ២០១៩
- ថវិកាគម្រោង: <u>**$392,800**</u>
- លទ្ធផលរំពឹងទុករយៈពេលមធ្យម: មានប្រាំចំណុចដូចខាងក្រោម:
  - ✓រៀបចំឡើងវិញនូវនីតិវិធីនានា សម្រាប់ធ្វើការប្រតិបត្តិ Online និងធ្វើប្រតិភូកម្ម
  - ✓ស្វ័យប្រវត្តិកម្មនៃការចេញវិញ្ញាបនប័ត្រ Online និងផ្តល់ឧបករណ៍ត្រួតពិនិត្យចល័ត
  - ✓កែទម្រង់ច្បាប់និងលិខិតបទដ្ឋាននានាដែលទាក់ទងនឹងផ្នែកនេះ
  - ✓ការចែករំលែកព័ត៌មានដល់ស្ថាប័នដទៃទៀត ពិសេសស្ថាប័នបញ្ជរតែមួយថ្នាក់ជាតិ
  - ✓និរន្តរភាពនៃស្ថាប័ន និងជាគំរូក្នុងកម្រៃសេវា

លទ្ធផលរំពឹងទុករយៈពេលវែងនៃគម្រោងនេះ គឺកាត់បន្ថយពេលវេលា និងការចំណាយសម្រាប់អ្នកនាំចេញក្នុងការទទួលបាននូវវិញ្ញាបនប័ត្របញ្ជាក់អនាម័យ និងភូតគាមអនាម័យនៅក្នុងប្រទេសកម្ពុជា។

**អង្គប្រជុំបានអនុម័តលើគម្រោងស្នើនេះ។**

## VI. **អនុសាសន៍ និងការណែនាំរបស់លោកជំទាវ រដ្ឋលេខាធិការ**

*ក្នុងនាមជាប្រធានគណៈកម្មការអនុវត្តគម្រោង* **លោកជំទាវ តឹករ៉ែត កំរេង** *បានផ្ដល់នូវអនុសាសន៍ និងការណែនាំមួយចំនួនដូចខាងក្រោម:*

- ✓ *អបអរសាទរចំពោះលទ្ធផលដែលសម្រេចបានកន្លងមកក្នុងក្របខ័ណ្ឌ* Trade SWAp, TDSP និង EIF ។
- ✓ *ស្នើឲ្យភ្នាក់ងារអនុវត្តគម្រោងដែលបានទទួលការអនុម័តថវិកាបន្ថែមទាំងបីខាងលើ ចាប់ផ្ដើមរៀបចំនូវឯកសារសម្រាប់ការងារលទ្ធកម្ម* (Specification or ToR) *និងដាក់ជូនមក* DICO *ដើម្បីអោយដំណើរការលទ្ធកម្មអោយបានឆាប់ដែលអាចធ្វើទៅបាន។*
- ✓ *ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា* (CDC) *ធ្វើការសហការណ៍ជាមួយ* DICO *និងជំនួយបច្ចេកទេសពីធនាគារពិភពលោកក្នុងការរៀបចំគម្រោងថ្មី* (Investment Tracking System and After Care Services) *អោយបានឆាប់ដែលអាចធ្វើទៅបាន ព្រោះរយៈពេលគម្រោងគឺនៅសល់តែប្រមាណ៩ខែតែប៉ុណ្ណោះ ។ គម្រោងសំណើនេះនឹងត្រូវដាក់ជូន* IC *ពិនិត្យនិងអនុម័ត នៅក្នុងកិច្ចប្រជុំ* IC *លើកក្រោយដែលរៀបចំឡើងនៅថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ២០១៤ ។*

*អាស្រ័យហេតុនេះសូម* **ឯកឧត្តម ទេសរដ្ឋមន្ត្រី** *មេត្តាជ្រាបជារបាយការណ៍ដ៏ខ្ពង់ខ្ពស់ ។*
*សូម* **ឯកឧត្តម ទេសរដ្ឋមន្ត្រី** *មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។*

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ មិថុនា ២០១៤

**ប្រធាននាយកដ្ឋាន**

បានឃើញ និង ឯកភាព
គោរពជូន ឯកឧត្តម ទេសរដ្ឋមន្ត្រី
មេត្តាជ្រាបជារបាយការណ៍ដ៏ខ្ពង់ខ្ពស់

Thani

**ឈៀង ពេជ្រ**

ចម្លងជូន:
- ខុទ្ទកាល័យ ឯកឧត្តមទេសរដ្ឋមន្ត្រី
- គ្រប់សមាជិក SSC-TD-TRI
- គ្រប់សមាជិក IC
- ឯកសារ - កាលប្បវត្តិ

19.06.2014

# PROVISIONAL AGENDA

## The 33rd Implementation Committee Meeting

June 10, 2014 at 9:00 A.M.

Venue: The Ministry of Commerce

| | | |
|---|---|---|
| 08:30-09:00 | • **Arrival of IC members** | |
| 09:00-09:10 | • **Welcome Remarks** | • LCT. Tekreth Kamrang, Secretary of State, MoC |
| 09:10-09:30 | • Progress of TDSP and EIF Implementation | • Mr. Chhieng Pich, Director, D/ICO |
| 09:30-10:00 | • Endorsement of New Proposals:<br>• Business Registration<br>• SPS Automation | • Representatives of Relevant Implementing Agencies |
| 10:00-10:20 | • Other businesses | • All |
| 10:20-10:30 | • **Wrap-up and closing remarks** | • LCT. Tekreth Kamrang, Secretary of State, MoC |

***Note:*** *This provisional agenda is subject to change.*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**KINGDOM OF CAMBODIA**
***Nation - Religion - King***

**ក្រសួងពាណិជ្ជកម្ម**
*Ministry of Commerce*
លេខ ១៩៧៧ ព.ណ....ល.ស.ព.ក

ភ្នំពេញ, ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៤

## សូមជម្រាបជូន

## ឯកឧត្តមនាយកសាលាតុមិន្តរដ្ឋបាល

**កម្មវត្ថុ ៖** សំណើសុំអញ្ជើញ ឯកឧត្តមនាយក ដែលជាសមាជិកគណៈកម្មការអនុវត្តន៍គម្រោង (IC) ចូលរួម កិច្ចប្រជុំ IC លើកទី៣៣។

**ជូនភ្ជាប់ ៖** របៀបវារៈនៃកិច្ចប្រជុំ

តបតាមកម្មវត្ថុខាងលើ នាងខ្ញុំសូមជម្រាបជូន **ឯកឧត្តម** មេត្តាជ្រាប ដើម្បីជំរុញការអនុវត្ត Trade SWAp ឲ្យមានសន្ទុះតាមការគ្រោងទុក ក្រសួងពាណិជ្ជកម្ម សូមអញ្ជើញសមាជិកគណៈកម្មការអនុវត្តន៍គម្រោង (IC) មកចូលរួមកិច្ចប្រជុំ IC លើកទី ៣៣ របស់គណៈកម្មការអនុវត្តន៍គម្រោងប្រចាំខែមិថុនា។

កិច្ចប្រជុំនេះ នឹងប្រព្រឹត្តទៅនៅថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៤ វេលាម៉ោង០៩:០០នាទី នៅសាលប្រជុំនៃក្រសួងពាណិជ្ជកម្មក្រោមអធិបតីភាព **លោកជំទាវ តឹករ៉េត កំរេខ** រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម តាមកម្មវិធីដូចមានចែងនៅក្នុងរបៀបវារៈជូនភ្ជាប់។

អាស្រ័យដូចបានជម្រាបជូនខាងលើសូម **ឯកឧត្តម** មេត្តាអញ្ជើញចូលរួមប្រជុំតាមកាលបរិច្ឆេទដោយក្តីអនុគ្រោះ ។

សូម **ឯកឧត្តម** ទទួលនូវការគោរពរាប់អាន អំពីនាងខ្ញុំ។

**ជ.រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
**រដ្ឋលេខាធិការ**

**តឹករ៉េត_កំរេខ**

ចម្លងជូន:
-ខុទ្ទកាល័យ ឯកឧត្តមទេសរដ្ឋមន្ត្រី
-ឯកសារ-កាលប្បវត្តិ

ទំនាក់ទំនងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ:
ទូរស័ព្ទ: ០១២-៨០៤-២៣០, ០១២-៨៧៦-៣២០
អ៊ីម៉ែល: manymamkh@yahoo.com, haoann2003@yahoo.com

## By the 11th Sub Steering Committee on Trade Development and Trade Related Investment

Ministry of Commerce , 16 August 2012

| No | Strategic Proposal Code | Strategic Proposal Title | Implmenting Agency | Ministry | Pillars | Budget (USD) | 22nd/Special IC Recommendation |
|---|---|---|---|---|---|---|---|
| 1 | TDSP2012-SP08 | Support to the Government-Private Sector Forum (G-PSF) | Cambodia Chamber of Commerce | Cambodia Chamber of Commerce | 2 | 260,338.50 | Approval for 2012-2013 |
| 2 | TDSP2012-SP09 | Develop a Stronger National System for IP Generation, Protection, Administration and Enforcement | Secretariat of National Committee for IPR/DIPR | National Committee for IPR/MoC | 1 | 148,491.00 | Approval for 2012-2013 |

Phnom Penh, 16 August, 2012

Agreed & Submitted by

PAN Sorasak
Secretary of State
Trade SWAp IC Chairman

Checked & Forwarded by

SOK Sopheak
Director General
Trade SWAp IC Permanent Member

Prepared by

HANG Sochivin
Trade SWAp IC Secretary

Seen & Approved by

CHAM Prasidh
Senior Minister-Minister of Commerce
Chairman of Sub Steering Committee on Trade Development and Trade Related Investment (SSC-TD.TRI)